# ការសំភាស៍របស់អ្នកមីងផន ថុន

កះ អ្នកដែរសំភាស៍គេគង់ អៀលី ខះ អ្នកដែលត្រូវគេសំភាស៍ឈ្មោះថា ផន ថុន

កះ អញ្ជឹងថ្ងៃនិងថ្ងៃទី២១ខែ០១ឆ្នាំ២០១៧ខ្ញុំឈ្មោះគង់
អៀលីហើយអឺតឡូវនិងខ្ញុំកំពុងស្ថិតនៅភូមិតា ព្រំ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ
រាជធានីភ្នំពេញ។អញ្ជឹងខ្ញុំសូមជំរាបសួរអ្នកមីងអញ្ជឹងខ្ញុំធ្វើ
ការអោយសកលវិទ្យាល័យមួយដែលកំពុងសកលវិទ្យាមួយនៅសហរដ្ឋអាមេរិចសកលវិទ្យានិង
មានឈ្មោះថាសកលវិទ្យាយBYUអញ្ជឹងសកលវិទ្យាមួយនេះគឺកំពុងតែធ្វើគំរោងដើម្បីអឺធ្វើគំរោមួយនិងដើម្បីជួយសំភាស៍អំពូមីងទាំងដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជានិងដើម្បីអោយគាត់
បានកត់ត្រាអំពីជីវប្រវិត្តរបស់អ្នកមីងគាត់ទុកអោយកូនចៅក្រោយៗរបស់អ្នកមីងគាត់បានដឹង

និងបានអឺស្គាល់អំពីការតស៊ូរបស់លោកពូអ្នកមីងទាំងអស់អញ្ជឹងអត់ទោសតើខ្ញុំអាចសូមសួរសំនួរអឺតើខ្ញុំអាចសុំសំភាស៍អ្នកមីងអំពីជីវប្រវិត្តរបស់អ្នកមីងបានទេតាំងពីកុមារភាពរហូតដល់ បច្ចុប្បន្ននិងបានទេ?

ខះ បាន។

កះ
អញ្ជឹងនៅពេលខ្ញុំសំភាស៍ខ្ញុំនិងសុំអ្នកមីងដើម្បីកត់ត្រាអំពីអ្វីដែលអ្នកមីងបាននិយាយដើម្បីទុក ជាការចងចាំដល់កូនចៅជំនាន់ក្រោយរបស់អ្នកមីងអញ្ជឹងសកលវិទ្យាល័យមួយនិង និងផ្តល់ ច្បាប់ចម្លងនៃការសំភាស៍មួយដល់អ្នកមីងហើយអ្នកមីងនិងអាចស្តាប់វា នៅលើគេហទំព័ររបស់
សកលវិទ្យាល័យBYUនៅពេលក្រោយនៅពេលអ្នកមីងចង់ស្តាប់និងចង់ឃើញវាអញ្ជឹងអាស្រ័យដ្ឋានបច្ចុប្បន្នរបស់អ្នកមីងនិងអ្វីដែល?

ខះ អាស្រ័យដ្ឋានបច្ចុប្បន្ននិងនៅភូមិស្វាយតាអុកស្រុកកៀនស្វាយខេត្តកណ្តាល។

កៈ អញ្ចឹងអ្នកមីងតើអ្នកមីងមានលេខទូរស័ព្ទផ្ទាល់ខ្លួនរបស់អ្នកមីង
ហើយលេខទូរស័ព្ទរបស់អ្នក មីងនិងលេខប៉ុន្មានដែល?

ខៈ 069 21 59 60។

កៈ អញ្ចឹងអរគុណសម្រាប់
អនុញ្ញាតអោយខ្ញុំសំភាស៍អ្នកមីងហើយខ្ញុំនិងសួរអ្នកមីងបន្ថែមទៀតអញ្ចឹង
អ្នកមីងមានឈ្មោះអ្វីដែលហើយឈ្មោះហៅក្រៅហើយឈ្មោះពីកុមារភាពដែលឬទេ?

ខៈ ចា ឈ្មោះខ្ញុំពីកុមារភាពគឺ....

កៈ ចា ឈ្មោះពេញណាអ្នកមីង.....

ខៈ ឈ្មោះពេញឈ្មោះ ផន ចុន។

កៈ ចា អ្នកមីង អញ្ចឹងឈ្មោះហៅក្រៅ?

ខៈ ឈ្មោះហៅក្រៅឈ្មោះតូច។

កៈ ចុះឈ្មោះពីកុមារភាពវិញ?

ខៈ កាលឈ្មោះពីកុមារភាពក៏ឈ្មោះថាតូចនិងដែល។

កៈ
អញ្ចឹងអ្នកមីងតើអ្នកមីងធ្លាប់រៀននិយាយភាសាក្រៅពីភាសាខ្មែរដែលទេឬកាលនិងអ្នកមីងបាន រៀនភាសាអ្វីខ្លះដែល?

ខៈ អញ្ចឹងភាសាដូចការកន្លងមកដែរដោយសារខ្ញុំបានរៀនតែភាសាអង់គ្លេស
បានរៀនបន្តិចបន្តួច
ហើយនិងអ៊ីរូមទាំងភាសាថៃខ្លះខ្ញុំអាចចេះមួយចំនួនដែលអាចនិយាយទិញអីវ៉ានគេអីខ្លះបាននិងសួរគេថាធ្វើដំណើរ ទៅ ណាមកណាអីអញ្ចឹងបាន

កៈ ចា!

ខៈ ភាសាថៃក៏អញ្ចឹងដែរ

កៈ អញ្ចឹងអ្នកមីងតើការនិយាយនិងការសរសេរជាភាសាខ្មែររបស់អ្នកមីង
បានដល់កំរិតណាដែល?

ខៈ ចា
កាលសរសេរនៃភាសាខ្មែរខ្ញុំបានត្រឹមបន្តិចបន្តួចដែលហើយការសរសេរក៏បានតិចដែល
ព្រោះ ខ្ញុំបានអឺម៉ាអាចមើលបា
នព្រោះមិនមានលុយទៅរៀននិងគេហើយទៅរៀនអក្សរនៅអក័រស័យធូរ
ពេលចេញពីសម័យពល់ពត់មក។

កៈ ចា
អញ្ចឹងអឺអ្នកមីងតើអ្នកមីងចាំថ្ងៃខែឆ្នាំកំណើតថាតើអ្នកមីងកើតនៅថ្ងៃខែឆ្នាំណាដែល?

ខៈ អឺថ្ងៃខែឆ្នាំកំណើត។

កៈ
អ្នកមីងអត់ចាំទេអញ្ចឹងអឺអ្នកមីងគិតចាប់ពីអាយុរបស់អ្នកមីងមករហូតមកដល់សព្វថ្ងៃនេះ?

ខៈ សព្វថ្ងៃនិងខ្ញុំមានអាយុ59ឆ្នាំហើយ។

កៈ
អញ្ចឹងអឺអ្នកមីងមានចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្ដាយឬក៏ទីកន្លែកដែលអឺរបស់គាត់កើត
ហើយ
ថាគាត់មានថ្ងៃខែឆ្នាំកំនើតណាហើយគាត់កើតនៅអឺទីកន្លែងកំនើតរបស់គាត់នៅឯណាដែ
លអ្នកមីង ?

ខៈ ថ្ងៃខែឆ្នាំកំនើតម្ដាយខ្ញុំគឺចាំថាគ្រាន់តែគាត់មាន
ជួន់អាយុ90ជាងហើយប្រហែលជាខ្ទង់និងហើយ ហើយបើឪពុកខ្ញុំវិញប្រហែល95ចា។

កៈ អញ្ចឹងអឺចុះទីកន្លែងកំនើតរបស់គាត់វិញ?

ខៈ ទីកន្លែងកំនើតរបស់គាត់
គាត់រស់នៅតាំងពីខ្ញុំនៅតូចមកពួកគាត់រស់នៅស្រុកកៀនស្វាយភូមិ
ស្វាយតាអុកយើងនិងតាំងពីដើមយើងមកនិង។

កៈ ចា!

ខ៖ និងហើយ

ក៖ អញ្ចឹងអ្នកមីងអឺអាយុពួកគាត់និងដល់ពេលឥឡូវនិងគាត់មានអាយុប៉ុន្មានហើយ?

ខ៖ អាយុគាត់គឺសម្រាប់ម្ដាយខ្ញុំគាត់អាយុ95ហើយ ហើយឪពុកខ្ញុំគាត់ខូចយូរណាស់ហើយប្រហែលជាជំនាន់និងប្រហែលជាខ្ទង់30ឬក៏38ក្បែងប៉ុនហ្នឹងឯង។

ក៖ អញ្ចឹងអ្នកមីងតើអ្នកមីងអាចចាំនៅថ្ងៃខែឆ្នាំកំនើតរបស់ជីដូនជីតារបស់អ្នកមីងដែលឬទេ?

ខ៖ ចាអឺគាត់ឆ្នាំកំនើតជីដូនជីតាខ្ញុំគាត់និយាយខ្ញុំប្រហែលជាអត់ចាំដែល។

ក៖ ចា អញ្ចឹងអ្នកមីងប្រសិនជារហូតពេលឥឡូវនិងពួកគាត់អឺលោកតាលោកយាយរបស់អ្នកមីងនិង មានអាយុប៉ុន្មានហើយ?

ខ៖ ប្រហែងជាគាត់ខូចខ្ទង់

ក៖ ចាប់ពីនិងរហូតមកដល់ឥឡូវគាត់មានអាយុប៉ុន្មានហើយប្រហែលប៉ុន្មានដែលទាំងជីដូនជីតា អត់អីទេអ្នកមីងបើអត់ចាំ?

ខ៖ ប្រហែលជាគាត់ខ្ទង់ចិតជាងហើយមិនដឹងនៅពេលដែលគាត់ខូចនិង

ក៖ អញ្ចឹងអ្នកមីអាចចាំតែពេលគាត់ស្លាប់ទេ?

ខ៖ ចា ចា ចា! អញ្ចឹងគាត់ប្រហែលជាខ្ទង់ប៉ុនហ្នឹងហើយ។

ក៖ អញ្ចឹងអឺអ្នកមីងអឺតើអ្នកមីងបានចាំនៅថ្ងៃរៀបការរបស់អ្នកមីងដែលទេថាតើអ្នកមីងរៀបការនៅ ថ្ងៃខែឆ្នាំណាដែរ?

ខ៖ ថ្ងៃរៀបការរបស់ខ្ញុំខ្ញុំគ្រាន់តែចាំថាចេញពីសម័យពល់ពតមកនិងម្ដាយចិញ្ចឹងរបស់ខ្ញុំបានរៀបការអោយខ្ញុំនៅក្នុងសារូនស័យធូរនិងរបស់មកដល់ស្រុកខ្មែរនេះសព្វថ្ងៃយើងនិង។

កៈ ចា
អញ្ជឹងអ្នកមីងការរៀបចំអាពាហ៍ពិពាហ៍និងប្រព្រឹត្តទៅយ៉ាងដូចម្តេចហើយការរៀបចំអាពាហ៍ពិពាហ៍របស់អ្នកមីងនិងគឺដោយឪពុកម្តាយរបស់អ្នកមីងឬក៏អ្វីផ្សេងទៀត?

ខៈ
ការរៀបអាពាហ៍ពិពាហ៍របស់ខ្ញុំនិងមានឪពុកម្តាយចិញ្ចឹងនខ្ញុំនិងគាត់ការអោយខ្ញុំឪពុកម្តាយខ្ញុំគាត់នៅឯស្រុកនេហើយយើងនៅព្រៃកអែងនេយើងអត់អាចជួបគាត់បាន

កៈ អ្នកមីងនៅជាមួយម្តាយចិញ្ចឹងនិងឪពុកចិញ្ចឹង?

ខៈ ឪពុកម្តាយចិញ្ចឹមខ្ញុំជាអ្នកការអោយខ្ញុំ

កៈ ចា
អញ្ចឹងការរៀបការរបស់អ្នកមីងនិងអីរបៀបថាប្រព្រឹត្តទៅនិងមានការប្រព្រឹត្តទៅមានការដូចម្តេចដែលវាពិបាកឬក៏វាងាយស្រួលអីអញ្ចឹង?

ខៈ
ក្នុងការរៀបការរបស់ខ្ញុំដែលឪពុកម្តាយចិញ្ចឹមខ្ញុំរៀបចំអោយនិងដូចថាអត់មានបញ្ហាអីទាំងអស់
ទាំងការយល់ព្រមពីឪពុកម្តាយទាំងឪពុកម្តាយចិញ្ចឹមខ្ញុំទាំងខ្ញុំគឺអត់មានបើនិយាយទៅបានទៅយ៉ាងល្អនិងរឡូនតែម្តងអត់មានបញ្ហាអីទេ។

កៈ អញ្ចឹងការរៀបការរបស់អ្នកមីងនិងនៅក្នុងជំនាន់ណាដែលអ្នកមីង?

ខៈ
ជំនាន់យើងចេញពីពល់ពតយើងនិងហើយហើយមានពួយបារាំងដែលគេមកចូលជួយយើងនៅក្នុងជំនុំ។

កៈ ចា អញ្ចឹងបែបពីអាពតមកបានអ្នកមីងរៀបការន៍?

ខៈ ចា ចា ចា!

កៈ ចា
អញ្ចឹងមីងតើខ្ញុំចង់ដឹងបន្ថែមទៀតអំពីការរៀបការរបស់អ្នកមីងអញ្ចឹងខ្ញុំចង់សួរអ្នកមីងអំពី

ការជួបគ្នាដំបូងជាលើកទីមួយជាលើកដំបូងរបស់អ្នកមីងនិងថាតើអ្នកមីអបានជួយគាត់យ៉ាងដូចម្ដេចបានជួបគ្នាយ៉ាងដូចម្ដេចអីអញ្ជឹងទៅ?

ខ៖
ការខ្ញុំបានជួយគ្រួសារខ្ញុំដំបូងគាត់មុនដំបូងគាត់បានចូលមកសើបតាមម្ដាយចិញ្ចឹងរបស់ខ្ញុំសួរថាខ្ញុំនិងមានទាក់ទងនិងណាគេហើយឬនៅ
តែម្ដាយចិញ្ចឹងខ្ញុំនិងខ្ញុំបានឆ្លើយប្រាប់ម្ដាយខ្ញុំនិងថាខ្ញុំនិងអត់ទាន់មានភ្ជាប់ពាក្យជាមួយនិងអ្នកណាទេអញ្ជឹងខ្ញុំក៏យល់ព្រមទៅជាមួយនិងម្ដ៏យល់ព្រមទៅជាមួយនិងម្ដាយចិញ្ចឹងខ្ញុំនិងទៅដែលគាត់សួរដែលអោយគ្រួសារខ្ញុំនិងឯងចា។

ក៖
អញ្ចឹងអ្នកមីងនៅពេលដែលអ្នកមីងរៀបការនិងអ្នកមីងបានស្គាល់ប្ដីរបស់អ្នកមីងហើយឬក៏អត់ ទាន់បានស្គាល់ទេគាត់ចូលដណ្ដឹងអ្នកមីងតែម្ដង?

ខ៖ ចា ខ្ញុំបានស្គាល់គាត់ហើយបានគាត់ចូលសួរខ្ញុំ

ក៖
អញ្ជឹងមិនមែនគាត់រៀបថាបានស្គាល់ហើយចូលស្គាល់តាមឪពុកម្ដាយអ្នករៀបខ្ញុំអីអោយ អញ្ជឹងអ្នកមីងបានស្គាល់គាត់ហើយអញ្ជឹង

ខ៖
ស្គាល់តាមឪពុកម្ដាយចិញ្ចឹងខ្ញុំព្រោះថាខាងប្រុសនិងខាងប្ដីខ្ញុំនិងគេមកសួរតាមរយះឪពុកម្ដាយខ្ញុំ ហើយក៏ចូលដណ្ដឹងតាមឪពុកម្ដាយចិញ្ចឹងខ្ញុំ។

ក៖ ចា
អញ្ចឹងអត់ទោសអ្នកមីងខ្ញុំចង់សួរអ្នកមីងអំពីជីវប្រវត្តិរបស់ជីដូនជីតារបស់អ្នកមីងតើអ្នកមីងនៅចងចាំអត់អំពីប្រវិត្តរបស់ជីដូនជីតារបស់អ្នកមីងនិង?

ខ៖
ប្រវិត្តរបស់ជីដូចជីតារបស់ខ្ញុំគាត់នៅស្រុកនិងតាំងពីដើមមកហើយដល់ពេលខ្ញុំនៅជំនុំជាមួយ
ម្ដាយចិញ្ចឹងរបស់ខ្ញុំខ្ញុំគ្រាន់តែចាំថាគាត់បានកាលពីពួកខ្ញុំនៅក្មេងៗគាត់រស់នៅទីនិងនៅ

ព្រែកអែងប៉ុន្តែខ្ញុំអត់ដឹងថាឡូវនេះគាត់បានខូចហើយឬក៏នៅទេគ្រាន់តែខ្ញុំដឹងថានៅពេលដែលខ្ញុំមកពីជំនុំវិញគាត់ខូចអស់ហើយ។

កៈ បើអញ្ចឹងស្ថានភាពជីដូនជីតារបស់អ្នកមីងនិងមានស្ថានភាពយ៉ាងមិចដែល?

ខៈ
ស្ថានភាពរបស់ជីដូនជីតារបស់ខ្ញុំតាំងពីដើមមកនិយាយទៅគាត់មិនមែនជាអ្នកធូរធាប៉ុនណាទេគ្រាន់តែថាស្ថានភាពរស់នៅរបស់គាត់ថាម៉ាល្មមដូចគេដូចឯងមិនមែនថាគាត់ជាអ្នកក្រពេកឬក៏ជាមានពេកដែលខ្ញុំគ្រាន់ដឹងតែប៉ុនហ្នឹងទេ។

កៈ
អញ្ចឹងអីអ្នកមីងតើអីក្រុមគ្រួសាររបស់អ្នកមីងឬក៏ជីដូចជីតារបស់អ្នកមីងគាត់ធ្លាប់ទៅរស់នៅឯក្រៅប្រទេសដែលទេក្រៅពីគាត់នៅខ្មែរនិង?

ខៈ
ក្រៅពីប្រទេសខ្មែរគាត់អត់ដែលរស់នៅក្រៅប្រទេសអីទេគាត់រស់នៅកៀនស្វាយនិងតែម្តងរហូតដល់គាត់ស្លាប់។

កៈ
អញ្ចឹងនៅពេលនិងគាត់រស់នៅប្រទេសខ្មែរទាំងអស់តែម្តងអត់បានទៅរស់នៅស្រុកក្រៅអីទេ?

ខៈ អត់ទេ!

កៈ
អញ្ចឹងអីអត់ទោសអ្នកមីងខ្ញុំចង់ដឹងអំពីជីវិតនិងការតស៊ូរបស់អ្នកមីងនិងថាតើជីវិតនៃការតស៊ូរបស់អ្នកមីងតាំងពីកុមារភាពមករហូតមកដល់ពេលបច្ចុប្បន្ននេះយ៉ាងមិចដែល?

ខៈ ជីវិតក្នុងការតស៊ូរបស់ខ្ញុំនិងគឺអីតាំងពីតូចមកនិយាយទៅខ្ញុំតស៊ូដល់ម្តាយខ្ញុំគាត់ហាត់ដែលក្រោយ
មកក៏ខ្ញុំតស៊ូជាមួយប្អូនៗនិយាយទៅទាំងការលំបាកជាទីបំផុតតែខ្ញុំចេះតែតស៊ូជាមួយម្តាយខ្ញុំទៅ ក្នុងការរកចិញ្ចឹងប្អូននិងជួយរកម្តាយដែលគាត់ពិបាកដែលនិង។

កៈ ចា អញ្ចឹងអ្នកមីងអីតើអ្នកមីងធ្លាប់បានរៀននៅអីធ្លាប់បានរៀនដែលទេ?

ខ៖ នៅពីកុមារភាពនៅក្នុងស្រុកខ្ញុំ
ខ្ញុំអត់ដែលបានរៀនទេហើយខ្ញុំបានរៀនច្រើនបានតែអក្សរបន្តិច
បន្តួចនៅសារម្យដែលចប់ពីអាពល់អាពត់និងមកពួកអង្គការគេបង្រៀនហើយនិងគ្រូខ្មែរយើង បង្រៀននៅសារម្យសយ័ធូរ តាំងពីនៅស្រុកនិងមកខ្ញុំអត់បានរៀនអក្សរខ្មែរស្មោះ។

ក៖
អញ្ចឹងអ្នកមីងខ្ញុំអឺចង់ដឹងអំពីជីវិតរបស់អ្នកមីងនៅពេលនៅជំនាន់ពល់ពតនិងតើអ្នកមីងមានការ ពិបាកអ្វីខ្លះ?

ខ៖
សម័យពល់ពតនិយាយរួមទៅខ្ញុំពិបាកខ្លាំងណាស់ពិបាកដែលពេលប្រើខ្ញុំអោយធ្វើការអីក៏ខ្ញុំមិន ដែលអសកម្មជាមួយនិងការងារដែលហើយមួយទៀតខ្ញុំខំប៉ុននិងហើយ
ខ្ញុំប្រឹងតស៊ូរាល់កិច្ចការ
លំបាកមិនដែលសានុកទាំងយប់ទាំងថ្ងៃទាំងអស់ទាំងការគេប្រើអីខ្ញុំមិនដែលអខាន
ព្រោះអីជំនាន់ និងគេមានក្រិត
វិន័យរបស់គេអ្នកណាអត់ធ្វើការគេសម្លាប់ចោលអញ្ចឹងដូចពួកខ្ញុំអីសុទ្ធតែសមនិង
ស្លាប់ដែលថ្ងៃមួយនោះមានបញ្ហាបន្តិចបន្តួចគេអោយខ្ញុំទៅដកខោអាវអ្នកដែលចូលថ្មីដូចគ្នាដល់ពេលដែលទៅដកខោអាវគេនិងគេចោតថាខ្ញុំដកខោអាវគេអស់ច្រើនតាមការពិតខ្ញុំធ្វើតែតាមតែ
បញ្ហារបស់គេទេមិនអាចដករបស់គេអស់ទេដល់មកជំនាន់និងរហូតដល់អឺគេអាយយោធាយកខ្ញុំទៅសម្លាប់ចោលតែដូចជាមេកងខ្ញុំនិងមេក្រុងខ្ញុំនិងគាត់អាណិតខ្ញុំ
ថាខ្ញុំអត់មានខុសអីទេហោតុអ្វីក៏
ទៅចាប់ខ្ញុំបានខ្ញុំនិងបានត្រលប់មកវិញរួចខ្លួនរស់ដល់សព្វថ្ងៃនិង។

ក៖ អញ្ចឹងតើអ្នកមីងក្រុមគ្រួសាររបស់អ្នកមីងនិងជាអ្នកធ្វើចំការឬក៏ជាអ្នករកស៊ីអ្វីផ្សេង?

ខ៖
ក្រុមគ្រួសាររបស់ម្តាយឪពុកខ្ញុំនិងគាត់ជាអ្នកធ្វើចំការនៅនិងស្រុកនិងហើយមុនដំបូងគាត់ធ្វើចំការ
ដំជាត្រសក់ដូចជាអីទៀតតិចតួចអញ្ចឹងទៅដល់ហើយគាត់អត់ធ្វើអីទៀតទេក្រៅពីនិងមានតែគាត់ទិញគេបន្ថែមយកទៅលក់អញ្ចឹងទៅណាហើយបន្លែនិងវាតិចពេកអញ្ចឹងទៅណា

ព្រោះអីយើងអត់អ៏អញ្ចឹងបន្លែយើងនិងវាតិចពេលក៏ទិញគេបន្ថែមទៀតមានដូចជាល្ពុតដូចជាផ្លែប៉ោងនិងគាត់ទិញបន្ថែមតែខ្ញុំគ្រាន់តែនិងតែប៉ុនហ្នឹងទេ។

កៈ អញ្ចឹងអ្នកមីងគាត់អត់មានបានធ្វើការងារអីក្រៅពីការធ្វើចំការទេ?

ខៈ អត់ទេមានតែការធ្វើចំការនិងធ្វើខ្លួនឯងខ្លះនិងទិញគេតែប៉ុន្មានទេ។

កៈ
អញ្ចឹងអីអ្នកមីងប្រភេទការងារអ្វីផ្សេងទៀតដែលអ្នកមីងធ្លាប់បានធ្វើនៅក្នុងជីវិតក្រៅពីការធ្វើចំការនិងរបស់អ្នកមីងនិងផ្ទាល់ឬក៏អ្នកមីងធ្លាប់បានធ្វើការងារអីផ្សេងក្រៅពីការងារចំការនិង?

ខៈ
អាចេញពីសម័យពល់ពតនិងមកខ្ញុំធ្លាប់ធ្វើការងារពីមុនមកដល់ខ្លួនឯងាពេលមុនដំបូងពេលដែលខ្ញុំទៅរៀន
ធ្វើនំប៉ុងហើយខ្ញុំក៏ចេះមានពួកថៃដែលគេហៅថាពួកលោតឆត្រ័និងគេអោយខ្ញុំបង្រៀនគេដើម្បីគេនិងអោយរបកដល់ខ្ញុំមួយអាទិត្យគេអោយរបកអង្គយើងនិងអឺពីរថង់
ពីរថង់និងហើយមួយថង់វាប្រហែលជាកន្លះតៅហើយប្រហែលជាបូនដប់កំប៉ុងទៀតខ្ញុំមានតែប៉ុននិងទេ។

កៈ ចា អញ្ចឹងអ្នកមីងតើអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែល?

ខៈ
បងប្អូនខ្ញុំមានប្រាំបីនាក់តែសម័យពល់ពតស្លាប់អស់បីនាក់ហើយសព្វថ្ងៃនៅសល់ប្រាំនាក់

កៈ
ចុះតើអ្នកមីងអាចនិយាយបន្តិចបានទេអំពីពួកគាត់ថាតើពួកគាត់មានជីវភាពយ៉ាងមិចដែលបងប្អូននាក់មីងនិងជីវភាពរបស់គាត់តើមានជីវភាពយ៉ាងមិចដែល?

ខៈ
បងប្អូនខ្ញុំរស់នៅសព្វថ្ងៃបើនិយាយទៅបងប្អូនខ្ញុំដែលរស់នៅសព្វថ្ងៃនិងប្រាំនាក់និងគេបូននាក់និងគេធូរធាជាងខ្ញុំចំនែកខ្ញុំខ្ញុំមានការលំបាកជាងគេហើយក៏អត់ជាងគេដែល។

កៈ
អញ្ចឹងអីអ្នកមីងតើបងប្អូនអ្នកមីងនិងឬក៏អ្នកមីងផ្ទាល់ធ្លាប់បានបង្កើតឬក៏ធ្វើឧបករណ៍ភ្លេងខ្មែរដែលទេ?

ខៈ ចាបងប្អូនខ្ញុំអត់មានទេ។

កៈ អត់ធ្លាប់ធ្វើជាឧបករណ៍ភ្លេងខ្មែរទេន៍?

ខៈ ចា អត់ទេ។ បើកាលពីជំនាន់តាខ្ញុំគាត់បានអីលេងភ្លេង

កៈ លេងភ្លេងអីគេដែល?

ខៈ
លេងភ្លេងការមានខមមានស្គរមានទ្រអ៊ូទ្រសោកមានអីគ្រប់មុខចាអញ្ចឹងគាត់ចេះសព្វគ្រប់។

កៈ ចា
អញ្ចឹងអីតើអ្នកមីងតើក្រៅពីប្រភេទជំនាញផ្សេងនិងតើក្រុមគ្រួសាររបស់អ្នកមីងនិងមានជំនាញ អ្វីផ្សេងទៀតអត់?ជំនាញន័យការរកស៊ីអ្វីផ្សេងទៀត?

ខៈ
ក្នុងការរកស៊ីរបស់ខ្ញុំផ្ទាល់ខ្ញុំមានជំនាញផ្សេងជាទិញអីវ៉ានគេមកលក់មកធ្វើជានំអីមកលក់ខ្លួនឯង
ខ្លះចៀនចេកចៀនទៅអីឬក៏នំបាញ់ជំនៀកធ្វើបង់ផ្អែមទៀតដែលយកមកអីគេមកធ្វើផ្អែលក់ដោយខ្លួនឯងអញ្ចឹងទៅយើងចេះតែថែមទៅចេះធ្វើជាទឹកស្ករទឹកអីអញ្ចឹងលក់ទៅនិងបាននិងហើយអញ្ចឹងក្នុងជីវិតនេះសម្រាប់អីសេចក្តីស្រលាញ់ជាមួយនិងកូនខ្ញុំក៏ចេះតស៊ូក្នុងជីវិតនិយាយរួមទៅរឿងរកស៊ីខ្ញុំពូកែធ្វើជានំផ្សេងៗហើយអីនំជើងជ្រូកឬក៏ជានំសមចេញសមជ្រុកកាលខ្ញុំរស់នៅជាមួយក្រុមគ្រួសារខ្ញុំអញ្ចឹងខ្ញុំអាចប្តូរមុខរបរគ្រប់យ៉ាងបានចា ចា។

កៈ
អញ្ចឹងអីអ្នកមីងសព្វថ្ងៃនិងអ្នកមីងរស់នៅតែម្នាក់ឯងឬក៏អ្នកមីងរស់នៅជាមួយប្តីអ្នកមីងបានជាប្តីអ្នកមីងចែកឋានហើយ?

ខ៖
ចារស់នៅសព្វថ្ងៃនិងគឺខ្ញុំរស់នៅដោយប្ដីខ្ញុំខូចជូរឆ្នាំហើយអញ្ចឹងខ្ញុំមានតែរស់នៅជាមួយពួក  កូនៗនិងចិញ្ចឹងកូនដោយទឹកដោះតាមសមត្ថភាពរបស់យើង។

ក៖
ខ្ញុំចង់សួរសំនួរបន្ថែមទៀតណាអ្នកមីងអំពីការលំបាករបស់អ្នកមីងនិងតើអ្នកមីងអាចប្រាប់ខ្ញុំបានទេអ្នកមីងអំពីពេលវេលានិងបញ្ហាដែលសែនលំបាកបំផុតក្នុងជីវិតរបស់អ្នកមីងនិងថាតើជាបញ្ហាដែលអ្នកមីងគិតថាវាពិបាកនិងគេចផុតជីវិតរបស់អ្នកមីងនិង?

ខ៖
ពិបាកបំផុតក្នុងពេលសព្វថ្ងៃនិងក្នុងការគ្រប់គ្រោងរាជហើយខ្ញុំចេះផ្គត់ផ្គង់ក្រុមគ្រួសារហើយទីមួយរកដើម្បីអោយកូនរៀនកុំអោយកូនល្ងង់ដូចជាខ្ញុំទៀត។

ក៖ អញ្ចឹងតើអ្នកមីងបានឆ្លង យ៉ាងមិចខ្លះ?

ខ៖
មួយរយះនេះខ្ញុំឆ្លងកាត់ឧបសគ្គអស់និងទាំងការលំបាកទាំងការស្រនុកនិងឆ្លងការត់គ្រប់

បេបយ៉ាងក្នុងប្រកបមុខរបរហើយនិយាយរួមហើយខ្ញុំប្តូទៅជាក្រុមគ្រួសារចិញ្ចឹងកូនទាំងអស់គ្នាហើយឧបសគ្គគឺការខ្ញុំប្រឹងតស៊ូ។

ក៖
អ្ហឹងអ្នកមីងតើអ្នកមីងមានបានចាំអ្វីខ្លះដែលល្អបំផុតក្នុងជិវិតរបស់អ្នកមីងនិងតើវាជាបទពិសោធន៍អ្វីដែលអ្នកគិតថាវាល្អបំផុត?

ខ៖
ល្អបំផុតខ្ញុំអាចរកសម្រាប់អោយយើងកូនពេលថ្ងៃក្រោយកូនវាចេះចិញ្ចឹងកូនណាបានទេថាកុំចងពេលកូនមានការងារច្បាស់លាស់យើងអាចពឹងលើគាត់ហើយដូចជាខ្ញុំរាល់ថ្ងៃនិងអញ្ចឹងបទពិសោធន៍គឺការរកស៊ីនិងចិញ្ចឹងកូន។

ក៖
អឺខ្ញុំអស់អរគុណអ្នកមីងដែលអនុញ្ញាអោយខ្ញុំសំភាស៍អ្នកមីងហើយដែលអ្នកមីងបាននិយាយមកកាន់ខ្ញុំអញ្ចឹខ្ញុំសូមសួរអ្នកមីងអំពីមួយសំនួរទៀតអំពីសកលវិទ្យាBYUដែលពួកខ្ញុំបាន

ចុះមក

សំភាស៍អញ្ចឹងតើអ្នកមីងគិតឬមានខ្ញុំណាប់អារម្មណ៍យ៉ាងដូចម្តេចក្នុងសកលវិទ្យាល័យមួយនិងដែលអ្នកមីអ។

ខ៖ ចា

អឺក្មួយអើការសំភាស៍បើតាមតែមីងដឹងខ្ញុំថាវាល្អសម្រាប់ខ្ញុំនិងសម្រាប់ក្មួយអ្នកសំភាស៍ជាកាល ចង់ដឹងនៅជាជិវិតពិត។

ក៖

អញ្ចឹងអ្នកមីងខ្ញុំសូមអនុញ្ញាតធ្វើការថតរូបមួយចំនួនតើអ្នកមីងអានុញ្ញាតថតរូបអ្នកមីងទេ?

ខ៖ ចាខ្ញុំអនុញ្ញាតអោយក្មួយថតរូបខ្ញុំ។

ក៖ អញ្ចឹងអ្នកមីងខ្ញុំអស់អរគុណច្រើន។